00636363

E19

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី១៨ ខែមករា ឆ្នាំ ២០១១

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ សាធារណៈ / Public

ចំណាត់ថ្នាក់ឯកសារដោយ កសចស

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើសុំដោះលែង នួន ជា ជាបន្ទាន់**

---

<u>ដាក់ដោយ៖</u>

**ក្រុមមេធាវីការពារក្ដី នួន ជា:**

**សុន អរុណ**

Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW

ព្រុំ ផល្លា

Annabrecht VOSSENBERG

(កម្មសិក្សាការីផ្នែកច្បាប់)

<u>ផ្ញើជូន៖</u>

**សហព្រះរាជអាជ្ញា**

លោកស្រី **ជា លាង**

លោក Andrew CAYLEY

**គ្រប់ក្រុមមេធាវីការពារក្ដីទាំងអស់**

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 18 / 01 / 2011
ម៉ោង (Time/Heure): 15:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

## I. សេចក្ដីផ្ដើម

១. អនុលោមតាមវិធាន ៨២(២) និងវិធាន ៦៨(៣) នៃវិធានផ្ទៃក្នុង អ.វ.ត.ក (វិធាន) ក្រុមមេធាវីការពារក្ដីជនជាប់ចោទ **នួន ជា** ("ក្រុមមេធាវីការពារក្ដី") សូមដាក់សំណើបន្ទាន់ ("សំណើ") នេះជូនអង្គជំនុំជម្រះសាលាដំបូង (អ.ជ.ស.ជ) ដើម្បីសុំដោះលែង **នួន ជា** ពីការឃុំឃាំងបណ្ដោះអាសន្នជាបន្ទាន់។ ដូចហេតុផលដែលបានបញ្ជាក់នៅខាងក្រោមនេះ ការបន្តឃុំខ្លួន **នួន ជា** នឹងជាការផ្ទុយនឹងបញ្ញត្តិនៃវិធាន៦៨ និងអាស្រ័យដូចនេះហើយបង្កើតបានជាការរំលោភសិទ្ធិរបស់គាត់ចំពោះការឃុំខ្លួនតាមបញ្ញត្តិនៃច្បាប់។

## II.ប្រវត្តិនីតិវិធី

២. **នួន ជា** ត្រូវបានចាប់ខ្លួនដោយអាជ្ញាធររបស់ អវតក និងត្រូវបានឃុំខ្លួនបណ្ដោះអាសន្នដោយសហចៅក្រមស៊ើបអង្កេត ("សចស") សម្រាប់រយៈពេលមួយឆ្នាំចាប់ពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧[1] ។ រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន **នួន ជា** ត្រូវបានពន្យារពេលមួយឆ្នាំបន្ថែមទៀតនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨[2] ហើយថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ននេះត្រូវបានបន្តមួយឆ្នាំទៀតនៅ

---

[1] សូមមើលឯកសារ C-6 "ដីកាបង្គាប់ឲ្យនាំខ្លួន" ចុះថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០០៧, ERN 00148692–00148693, ឯកសារ C-7 "កំណត់ហេតុនៃការនាំខ្លួនជនសង្ស័យ" ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧, ERN 00148694–00148695, ឯកសារ C-8 "កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចពិភាក្សាដេញដោល" ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧, ERN 00148696–00148700 និង ឯកសារ C-9 "ដីកាឃុំខ្លួនបណ្ដោះអាសន្ន" ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧, ERN 00148701–00148705 ។ នៅឯបណ្ដឹងឧទ្ធរណ៍ ដីកាឃុំខ្លួនបណ្ដោះអាសន្ននេះ ត្រូវបានតម្កល់ដោយអង្គបុរេជំនុំជម្រះ ("អបជ")។ សូមមើលឯកសារ C-11/4 "បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្ន" ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧, ERN 00149999–00150442 និង ឯកសារ C-11/54 "សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្ន" ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ ២០០៨, ERN 00172907–00172934 ។

[2] ឯកសារ C-9/3 "ដីកាសម្រេចពីការពន្យារថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន" ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨, ERN 00224203–00224204។ នៅឯបណ្ដឹងឧទ្ធរណ៍ ដីកាសម្រេចពីការពន្យារថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ននេះ ត្រូវបានតម្កល់ដោយអង្គបុរេជំនុំជម្រះ។ សូមមើលឯកសារ C-9/4/1 "បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចពីការពន្យារថិរវេលានៃការឃុំខ្លួនបណ្ដឹងអាសន្ន នួន ជា" ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៨, ERN 00232728–00232736 និង ឯកសារ C-9/4/6 "សាលដីកាបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចពីការពន្យារថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន នួន ជា ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ ២០០៩, ERN 00303454–00303470 ។

ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩[3]។ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ សចស បានចេញដីកាបន្តការឃុំខ្លួនរហូតដល់គាត់នឹងត្រូវ "នាំខ្លួនទៅជំនុំជម្រះចំពោះមុខអង្គជំនុំជម្រះសាលាដំបូង"[4]។ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះ ("អបជ") បានសម្រេចបន្តឃុំខ្លួនបណ្ដោះអាសន្នរហូតដល់ **នួន ជា** ត្រូវបាន "នាំបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង"[5]។ បច្ចុប្បន្ននេះ **នួន ជា** ត្រូវឃុំខ្លួននៅមន្ទីរឃុំឃាំងរបស់ អវតក ក្រោមការគ្រប់គ្រងនិងត្រួតពិនិត្យដោយក្រសួងមហាផ្ទៃនៃរាជរដ្ឋាភិបាលកម្ពុជា។

## III. ច្បាប់ពាក់ព័ន្ធ

### ក. សំណើសុំដោះលែង

៣. អនុលោមតាមវិធានផ្ទៃក្នុង "ជនជាប់ចោទ ឬមេធាវីជនជាប់ចោទអាចស្នើសុំដោយ [...] លិខិតជាលាយលក្ខណ៍អក្សរ ដាក់ជូនក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូងឲ្យដោះលែងជនជាប់ចោទ"។ អង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចអំពីបញ្ហានេះ "បន្ទាប់ពីបានស្ដាប់ជនជាប់ចោទ មេធាវីជនជាប់ចោទ និងសហព្រះរាជអាជ្ញា"។ អង្គជំនុំជម្រះសាលាដំបូងអាច "គ្រប់ពេលនៃកិច្ចដំណើរការនីតិវិធី" បង្គាប់ឲ្យដោះលែងជនជាប់ចោទ[6]។

### ខ. អានុភាពរបស់ដីកាដំណោះស្រាយលើការឃុំខ្លួនបណ្ដោះអាសន្ន

៤. វិធាន៦៨ចែងពីអានុភាពរបស់ដីកាដំណោះស្រាយទៅលើការឃុំខ្លួនបណ្ដោះអាសន្នដូចខាងក្រោម៖

> ១. ការចេញដីកាដំណោះស្រាយមានអានុភាពបញ្ចប់ឃុំខ្លួនបណ្ដោះអាសន្ន [...] និងដីកាសម្រេចទាំងឡាយនៅពេលដែលរយៈពេលកំណត់ នៅក្នុងការប្ដឹងឧទ្ធរណ៍ត្រូវផុត

---

[3] ឯកសារ C-9/6 "ដីកាសម្រេចពីការពន្យារថិរៈវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន" ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០០៩, ERN 00375956–00375965។ មេធាវីការពារក្ដីមិនប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកានេះទេ ។

[4] ឯកសារលេខ D427, កសចស "ដីកាដំណោះស្រាយ" ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០, ERN 00604508–00605246, at ERN 00604909។

[5] ឯកសារ D427/2/12 "សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ" ១៣ មករា ឆ្នាំ២០១១, ERN 00634916-00634922, at ERN 00634922។

[6] វិធាន ៨២

> រលត់។ ប៉ុន្តែនៅពេលដែលសហចៅក្រមស៊ើបអង្កេតយល់ឃើញថាលក្ខខណ្ឌទាំងឡាយសម្រាប់បង្គាប់ឲ្យឃុំខ្លួនបណ្ដោះអាសន្ន [...] ក្រោមវិធាន៦៣ នៅតែតម្រូវសហចៅក្រមស៊ើបអង្កេតសម្រេចបន្តឃុំជនជាប់ចោទបណ្ដោះអាសន្នតទៅទៀត [...] រហូតដល់ជនជាប់ចោទនេះ ត្រូវនាំខ្លួនទៅជំនុំជម្រះនៅអង្គជំនុំជម្រះសាលាដំបូង ។
>
> ២. នៅពេលមានបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ អានុភាពនៃដីកាសម្រេច [របស់សហចៅក្រមស៊ើបអង្កេត] រក្សាជនជាប់ចោទនៅក្នុងឃុំបណ្ដោះអាសន្ន ត្រូវបន្តមានអានុភាពអនុវត្តរហូតមានសេចក្ដីសម្រេចពីអង្គបុរេជំនុំជម្រះ។ អង្គបុរេជំនុំជម្រះត្រូវសម្រេចក្នុងអំឡុងពេល៤ខែ ។
>
> ៣. នៅក្នុងករណីណាក៏ដោយ សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ឬសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដើម្បីបន្តរក្សាទុកជនជាប់ចោទនៅក្នុងការឃុំខ្លួនបណ្ដោះអាសន្ន [...] ត្រូវអស់អានុភាពក្នុងរយៈពេលបួន(៤)ខែក្រោយ លើកលែងតែជនជាប់ចោទត្រូវបាននាំខ្លួនទៅជំនុំជម្រះនៅអង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេលនោះ [7]។

## គ. ភាពចាំបាច់មាន សំអាងហេតុ

៥. វិធាន ៧៧(១៤) ចែងដែលទាក់ទងថា "សេចក្ដីសម្រេចទាំងអស់ស្ថិតក្នុងវិធាននេះ [...] ត្រូវមានសំអាងហេតុ [...]"។ សេចក្ដីសម្រេចកាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ គឺជា "សេចក្ដីសម្រេចក្រោមវិធាននេះ" (វិធាន ៧៧) និងដូច្នេះត្រូវតែមានសំអាងហេតុ។

៦. ចំពោះការនិយាយជាទូទៅអំពីការតម្រូវឲ្យមាន "សំអាងហេតុ" គឺចិតនៅក្រោមប្រព័ន្ធទាំងមូលនៃវិធាន និងហេតុដូចនេះ អវតកៈ ស្ទើរតែនៅគ្រប់សកម្មភាពជាវិជ្ជមានដែលត្រូវអនុវត្តដោយភាគីនានា (កសព កសចស មេធាវីកាពារ អបជ និង អជសង) ត្រូវតែ "មានសំអាងហេតុ"[8]។

---

[7] បញ្ញត្តិដូចគ្នានៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា អាចប្រៀបធៀបបាននឹងវិធាន៦៨ ក៏ប៉ុន្តែខុសនឹងវិធានត្រង់ថា មិនអាចប្ដឹងឧទ្ធរណ៍នឹងដីកាដំណោះស្រាយបាន។ សូមមើលមាត្រា ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា: ("ដីកាដំណោះស្រាយបញ្ចប់ការឃុំខ្លួនបណ្ដោះអាសន្ន។ [...] តាមសេចក្ដីសម្រេចដោយឡែកនៃដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរអាចរក្សាជនត្រូវចោទឲ្យនៅជាប់ឃុំបណ្ដោះអាសន្ន រហូតដល់ពេលចូលបង្ហាញខ្លួននៅមុខតុលាការ។ [...] សេចក្ដីសម្រេចរក្សាជនត្រូវចោទក្នុងឃុំជា បណ្ដោះអាសន្នលែងមានអានុភាពក្នុងរយៈពេលបួន (៤)ខែ។ ប្រសិនបើជនត្រូវចោទមិនបានចូលទៅបង្ហាញខ្លួននៅមុខតុលាការក្នុងរយៈពេលបួន(៤)ខែ នោះទេ ជនត្រូវចោទនេះត្រូវបានដោះលែងឲ្យនៅក្រៅឃុំបណ្ដោះអាសន្នដោយឯកឯង)។

[8] សូមមើលវិធាន ២៩(៤), ៣២, ៤៤(២), ៥៥(១០), ៥៨(៦),៥៩(៥), ៦៣(១) (ខ), ៦៣(២)(ក), ៦៣(៧), ៦៤(២) ,៦៦(២) , ៦៧(៤),៦៨(១) ,៧១(៤)(គ), ៧២(៤)(ង), ៧៦(១), ៧៦(២) ,៧៧(១៤), ៧៩(៦)(ខ), ៧៩(៦)(គ), ៨៩(៣), ៩៩(២), ១០១(១)(ក), ១០៩(៣), ១១១(១), ១១១(៥)។



00636366

៧. ការតម្រូវឱ្យសេចក្តីសម្រេចមានសំអាងហេតុ គឺវាឆ្លុះបញ្ចាំងពីបទដ្ឋានគតិយុត្តិអន្តរជាតិ ដូចជាក្នុងតុលាការសិទ្ធិមនុស្សអឺរ៉ុប៖

> នៅក្នុងច្បាប់របស់ខ្លួន តុលាការជាញឹកញាប់បានប្រកាសថា សំអាងហេតុដែលបានផ្តល់ក្នុងសេចក្តីសម្រេច គឺទាក់ទងយ៉ាងជិតស្និទទៅនឹងសេចក្តីបារម្ភដើម្បីធានាឱ្យបានតុលាការត្រឹមត្រូវ ដើម្បីធានាបាននូវសិទ្ធិការពារក្តី។ ការសំអាងហេតុគឺសំខាន់ណាស់សម្រាប់យុត្តិធម៌ដ៏មានគុណភាព និងផ្តល់នូវការការពារប្រឆាំងនឹងសេចក្តីសម្រេចមិនសមរម្យ[9]។

## ឃ. ច្បាប់ និងនីតិវិធាជាធរមានរបស់ អវតក

៨. រដ្ឋធម្មនុញ្ញចែងថា "ការចោទប្រកាន់ ការចាប់ខ្លួន ឬការឃុំខ្លួនជនណានឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តទៅតាមបញ្ញត្តិច្បាប់"[10]។

៩. ការសំអាងរដ្ឋធម្មនុញ្ញ (ព្រមទាំងបទប្បញ្ញត្តិដែលពាក់ព័ន្ធនៃកតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ 'ICCPR')[11], កិច្ចព្រមព្រៀង និងច្បាប់បង្កើត អវតក (ព្រមជាមួយ "លិខិតុបករណ៍

---

[9] *រឿងក្តី Taxquet* តទល់នឹងប្រទេស បែលហ្ស៊ិក, តុលាការសិទ្ធិមនុស្សអឺរ៉ុប, ថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៩, ពាក្យសុំ No.926/05, កថាខណ្ឌទី៤៣ ។ រឿងក្តីនេះ និយាយយោងទៅរកអង្គជំនុំជម្រះតុលាការកំពូលដែលបានគាំទ្រសំអាងហេតុ។ សូមមើល *រឿងក្តី Taxquet* តទល់នឹងប្រទេស បែលហ្ស៊ិក, តុលាការសិទ្ធិមនុស្សអឺរ៉ុប, ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០, ពាក្យសុំ No.925/05, កថាខណ្ឌទី៩០ ដល់ ៩១ ។ សូមមើលផងដែរ *រឿងក្តី Hadjianastassiou* តទល់នឹងប្រទេសក្រិច, សាលដីកា, តុលាការសិទ្ធិមនុស្សអឺរ៉ុប, ពាក្យសុំ No.12945/87, ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩២, កថាខណ្ឌទី៣៣ ។សេចក្តីសម្រេចនេះ ក៏ទទួលបានការគាំទ្រក្នុងរឿងក្តី *Taxquet* តទល់នឹងប្រទេស បែលហ្ស៊ិក (ឆ្នាំ២០១០) ផងដែរ, កថាខណ្ឌទី៩១ ។

[10] រដ្ឋធម្មនុញ្ញ មាត្រា ៣៨ ។

[11] សូមមើល ICCPR មាត្រា៩(១) ("គ្មានបុគ្គលណាម្នាក់ត្រូវបានគេដកហូតសេរីភាពនោះទេ លើកលែងតែការដកហូតនោះធ្វើឡើងតាមហេតុផលច្បាប់ និងស្របតាមនីតិវិធីដែលបង្កើតដោយច្បាប់")។ មាត្រា ១៤(១) ("ក្នុងការសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួន ជនគ្រប់រូបត្រូវមានសិទ្ធិចំពោះ [...] ការជម្រះក្តីដោយ [...] តុលាការដែលបង្កើតឡើង*ដោយច្បាប់*), មាត្រា ១៤(២) ("ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌ ត្រូវបានសន្មតជាមុនថាជាជនគ្មានទោសរហូតដល់ពិរុទ្ធភាពរបស់ខ្លួន *ត្រូវបានកំណត់ស្របតាមច្បាប់*, មាត្រា ១៤(៥) ("ជនគ្រប់រូបដែលជាប់ពិរុទ្ធពីបទព្រហ្មទណ្ឌ ត្រូវមានសិទ្ធិសុំឱ្យតុលាការជាន់ខ្ពស់ពិនិត្យទៅលើការប្រកាសពិរុទ្ធភាព និងការផ្តន្ទាទោសឡើងវិញ*ស្របតាមច្បាប់*) និង មាត្រា ១៦ ("ជនគ្រប់រូបមានសិទ្ធិឱ្យគេទទួលស្គាល់បុគ្គលិកលក្ខណៈគតិយុត្តិរបស់ខ្លួននៅគ្រប់ទីកន្លែង (បញ្ជាក់បន្ថែម)។ សូមកត់សំគាល់ថាអង្គជំនុំជម្រះទាំងអស់របស់អង្គជំនុំជម្រះវិសាមញ្ញ "ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនឱ្យស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការត្រឹម

ធម្មនុញ្ញ") ទទួលស្គាល់គោលការណ៍នីត្យានុកូលភាព: "នីតិវិធី" ដែលបានអនុវត្តនៅអវតក "ត្រូវតែអនុវត្តតាមបញ្ញត្តិច្បាប់កម្ពុជា"[12] ហើយការចោទប្រកាន់ ការស៊ើបអង្កេត និងការជម្រះក្តីជនណាម្នាក់ ត្រូវអនុវត្តតាមនីតិវិធីដែលមានស្រាប់"[13]។ ជាពិសេសលក្ខខណ្ឌនៃការចាប់ខ្លួន និងការឃុំខ្លួនជនជាប់ចោទ ត្រូវតែស្របតាមច្បាប់ដែលមានស្រាប់"[14]។

## ង. ដំណោះស្រាយខ្ពស់បំផុត (ulrimum remedium)

១០. គោលការណ៍នៃការសម្រេចខ្ពស់បំផុតដែលត្រូវបានគេទទួលស្គាល់ជាអន្តរជាតិ ដែលចែង "នៅករណីមានមធ្យោបាយផ្នែកច្បាប់ដទៃទៀត ដែលអាចការពារផលប្រយោជន៍ខាងយុត្តិធម៌ ដោយមិនចាំបាច់បញ្ជូនត្រឡប់ទៅក្នុងពន្ធនាគារវិញ ឧទាហរណ៍ តាមរយៈការដោះលែងឲ្យមានសេរីភាព ឬ ដាក់នៅក្រោមការត្រួតពិនិត្យរបស់តុលាការ ដែលជាជម្រើសមួយត្រូវតែបានអនុវត្ត"[15] អាចអនុវត្តបានដូចគ្នានៅ អវតក ដោយសារតែគោលការណ៍នេះត្រូវបានទទួលស្គាល់នៅក្នុងមាត្រា ៩(៣) នៃ ICCPR[16]។ មាត្រា ៩(៣) ចែងថា "ការឃុំខ្លួនមនុស្សដើម្បីរង់ចាំការជំនុំជម្រះក្តី មិនមែនជាវិធានការទូទៅទេ...។ បទបុបញ្ញត្តិនេះ ត្រូវបានគាំទ្រដោយក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធានផ្ទៃក្នុង។ ឧទាហរណ៍វិធាន ៦៨ ចែងពីអនុភាព បញ្ចប់ដីកាឃុំខ្លួនបណ្តោះអាសន្ន ហើយមាត្រា ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចែងពីការ ដោះលែង ជនជាប់ចោទឲ្យនៅក្រៅឃុំដោយឯកឯង បន្ទាប់ពីផុតកំណត់នៃរយៈពេលបួនខែ។ ចំនុចបង្ហាញពីភាពលម្អៀងចំពោះស្ថានភាពដែលជនជាប់ចោទអាចត្រូវដោះលែងជាបណ្តោះអាសន្ន ប្រសិនបើ..."។

---

ត្រូវតាមច្បាប់ ដូចដែលមានចែងនៅក្នុងមាត្រា ១៤ និង ១៥ នៃកតិការសញ្ញា ICCPR ឆ្នាំ១៩៦៦ ដែលប្រទេសកម្ពុជាជាហត្ថលេខី" ។ មាត្រា ១២(២), សូមមើលផងដែរមាត្រា ៣៥ថ្មី នៃច្បាប់បង្កើត អវតក ។

[12] កិច្ចព្រមព្រៀង មាត្រា១២(១) ។ សូមមើលផងដែរ ឯកសារ E188 "សាលក្រមឌុច" ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ERN 00572517-00572797, កថាខណ្ឌ៣៥, 00572534 ។

[13] មាត្រា ២០ថ្មី, មាត្រា ២៣ថ្មី និងមាត្រា ៣៣ថ្មី នៃច្បាប់បង្កើត អវតក ។

[14] មាត្រា ៣៣ថ្មី នៃច្បាប់បង្កើត អវតក (បញ្ជាក់បន្ថែម)។

[15] លោក Geert-Jan Alexander Knoops, ទ្រឹស្តី និងការអនុវត្តន៍ នីតិវិធីព្រហ្មទណ្ឌអន្តរជាតិ និងនីតិវិធីព្រហ្មទណ្ឌដែលគេធ្វើឲ្យមានលក្ខណៈជាអន្តរជាតិ (Kluwer 2005), ទំព័រទី១៥១។

[16] មាត្រា៩(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិប្រជាពលរដ្ឋ និងនយោបាយ("ICCPR") ចែងថា៖ វាមិនមែនជាវិធានទូទៅទេកាលដែលថាបុគ្គលដែលរង់ចាំការជំនុំជម្រះក្តី ចាំបាច់ត្រូវតែជាប់ឃុំ [...]។

## IV. អំណះអំណាង

### ក. សំណើសុំដោះលែងនេះ អាចទទួលយកបាន

១១. បន្ទាប់ពីដីការបញ្ជូនរឿងទៅជំនុំជម្រះដោយ អបជ កាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ អជសដ បច្ចុប្បន្នកំពុងកាន់សំណុំរឿង។ អជសដ អាច "គ្រប់ពេល" នៃកិច្ចដំណើរការនីតិវិធី ដោះលែងជនជាប់ចោទ។ ជនជាប់ចោទក៏អាចស្នើដល់ អជសដ ឱ្យដោះលែងខ្លួន។ ការបកស្រាយសមស្របថា សំណើបែបនេះ អាចដាក់ "គ្រប់ពេល"នៃកិច្ចដំណើរការនីតិវិធី[17]។ អាស្រ័យហេតុនេះ សំណើនេះ អាចទទួលយកបាន។

### ខ. នួន ជា ត្រូវតែបានដោះលែងជាបន្ទាន់ ដោយសារដីកាឃុំខ្លួនបណ្តោះអាសន្នចុងក្រោយរបស់ សចស អស់អានុភាព និង អបជ មិនបានចេញ "សេចក្តីសម្រេច" ដូចដែលបានតម្រូវដោយវិធាន៦៨

១២. អនុលោមតាមវិធាន ៦៨(៣) ដីកាចុងក្រោយរបស់ សចស ក្នុងការបន្តឃុំខ្លួន **នួន ជា** អស់អានុភាព សម្រាប់រយៈពេល៤ (បួន)ខែ បន្ទាប់ពីកាលបរិច្ឆេទចេញដីកាដំណោះស្រាយរបស់ខ្លួន (នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០) លុះត្រាតែជនជាប់ចោទត្រូវបាននាំខ្លួនទៅអង្គជំនុំជម្រះសាលាដំបូងនៅមុនរយៈពេលនេះ។ **នួន ជា** មិនបាននាំខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេល៤ខែនេះ។

១៣. អនុលោមតាមច្បាប់ដដែលនេះ ប្រសិនបើដីកាដំណោះស្រាយត្រូវបានប្តឹងឧទ្ធរណ៍ ការបន្តការឃុំខ្លួនបណ្តោះអាសន្ន អាចពន្យារទៀតបានដោយសេចក្តីសម្រេចរបស់ អបជ លើបណ្តឹងឧទ្ធរណ៍។ អបជ បានចេញសេចក្តីសេម្រេចបែបនេះ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១។ ក៏ប៉ុន្តែសេចក្តីសម្រេចនេះមិនអាចចាត់ទុកថាជា "សេចក្តីសម្រេច" ឡើយ នៅក្រោមវិធាន ៦៨(២) និង (៣) និងត្រូវតែចាត់ទុកថា មិនអាចទទួលយកបាន។

---

[17] ទាំង កសចស និង អបជ លែងគ្រប់គ្រងសំណុំរឿងទៀតហើយ ហើយ កសចស និងអបជ នឹងប្រកាសថាសំណើរសុំដោះលែងនៅក្រៅឃុំ គឺមិនអាចទទួលយកបានដោយផ្អែកតែលើមូលដ្ឋាននេះតែមួយប៉ុណ្ណោះ។ ប្រព័ន្ធវិធានពាក់ព័ន្ធ ក៏ដូចជាបទដ្ឋានអន្តរជាតិ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌ បានទទួលស្គាល់យ៉ាងច្បាស់នូវសិទ្ធិរបស់ជនជាប់ចោទ នៅគ្រប់ពេលវេលាទាំងអស់ក្នុងការដាក់សំណើទៅតុលាការសុំដោះលែងឱ្យនៅក្រៅឃុំ ។ នៅក្នុងដំណាក់កាលនីតិវិធីបច្ចុប្បន្ន អង្គជំនុំជម្រះសាលាដំបូង គឺជាស្ថាប័នតុលាការដែលសាកសមជាងគេបំផុតក្នុងការពិចារណាពីសំណើសុំនៅក្រៅឃុំនេះ។

១៤. វិធាន ៧៧ ចែងថា រាល់សេចក្តីសម្រេចរបស់ អបជ ត្រូវមានសំអាងហេតុ។ តែសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ពុំមានសំអាងហេតុទេ។ ផ្ទុយទៅវិញសេចក្តីសម្រេចលើកឡើងថា "ការចេញសំអាងហេតុសម្រាប់គាំទ្រសាលដីកានេះ នឹងធ្វើទៅតាមពេលវេលាសមស្រប"[18]។ សេចក្តីសម្រេចរបស់ អបជ ដែលមិនមានសំអាងហេតុ គឺចាត់ទុកថា មិនមានជា "សេចក្តីសម្រេច" ដូចដែលបង្កើតដោយវិធាន។ អាស្រ័យហេតុនេះ អបជ មិនទាន់អាចត្រូវបានចាត់ទុកថា បានចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ដូចដែលបានតម្រូវដោយវិធាន និងមិនទាន់បានពន្យារការឃុំខ្លួនបណ្តោះអាសន្ន នៅឡើយទេ។ និយាយម៉្យាងទៀតថា សេចក្តីសម្រេចដែលចេញដោយ អបជ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ មិនបានផ្តល់មូលដ្ឋានច្បាប់គ្រប់គ្រាន់សម្រាប់ការឃុំខ្លួនបណ្តោះអាសន្នលើ **នួន ជា** បានឡើយ។

១៥. ដោយសារសេចក្តីសម្រេចរបស់ កសចស បន្តឃុំខ្លួន **នួន ជា** បានអស់អានុភាពនៅត្រឹមថ្ងៃទី១៥ ខែមករា ឆ្នាំ២០១១, ហើយ អបជ មិនបានចេញ "សេចក្តីសម្រេច" អនុលោមតាមនិយមន័យលើលក្ខខណ្ឌនេះ នៅក្រោមវិធាន ដូចនេះការបន្តឃុំខ្លួនបណ្តោះអាសន្នលើរូបគាត់គឺខ្វះមូលដ្ឋានច្បាប់គ្រប់គ្រាន់ និងគាត់ត្រូវតែបានដោះលែង។

## គ. សកម្មភាពរបស់ អបជ បង្ហាញពីការមិនគោរពយ៉ាងខ្ជាប់ខ្ជួនលើគោលការណ៍ ដំណោះស្រាយខ្ពស់បំផុត (ulrimum remedium) និងសិទ្ធិរបស់ នួន ជា

១៦. ហេតុផលតែមួយគត់ដែលថា សេចក្តីសម្រេចនេះមិនមានសំអាងហេតុគ្រប់គ្រាន់ដើម្បីសន្និដ្ឋានថា នេះមិនមែនជា "សេចក្តីសម្រេច" ដោយអនុលោមតាមវិធាន និងថា **នួន ជា** ត្រូវតែបានដោះលែង[19]។ សេចក្តីសន្និដ្ឋាននេះ ក៏គាំទ្រដោយ ប៉ុន្តែមិនពឹងផ្អែកលើមូលហេតុដែលថា សកម្មភាពរបស់ អបជ បង្ហាញពីការមិនគោរពយ៉ាងច្បាស់លើគោលការណ៍ដំណោះស្រាយខ្ពស់បំផុត

---

[18] ឯកសារ D427/2/12 "សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ" ១៣ មករា ឆ្នាំ២០១១, ERN 00634916-00634922, at ERN 00634922។

[19] ពិតណាស់ នៅទីបំផុត មេធាវីការពារក្តី គ្មានមន្ទិលសង្ស័យ អ្វីទេដែលថាហេតុផល នឹងត្រូវបានគេផ្តល់ឲ្យដើម្បីគាំទ្រសេចក្តីសម្រេចនេះ។ មេធាវីការពារក្តី គ្រាន់តែចង់គូសបញ្ជាក់ថា រយៈពេលកំណត់ដូចដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង គឺដើម្បីធានាថា ក្នុងរយៈពេល៤ខែ ជនជាប់ចោទ បានទទួលសេចក្តីសម្រេចមួយដែលមានសំអាងហេតុ មិនមែនគ្រាន់តែជាសេចក្តីសម្រេចធម្មតាៗនោះទេ។

(ulrimum remedium) និងដូចនេះហើយ ក៏មិនគោរពដល់សិទ្ធិរបស់ **នួន ជា** ដែរ។

១៧. នៅក្នុងភាពយុត្តិធម៌ គឺមិនអាចបដិសេធបានទេដែលថា អបជ បានចេញសេចក្តីសម្រេចក្នុងរយៈពេលបួនខែដើម្បីបញ្ចៀសការដោះលែង **នួន ជា** ដោយស្វ័យប្រវត្តិ។ វាជាហេតុផលល្អឥតខ្ចោះសម្រាប់ អបជ ចេញសេចក្តីសម្រេចមួយដែលតាមទស្សនៈរបស់ខ្លួនដើម្បីការពារមិនឲ្យមានការដោះលែងជនជាប់ចោទ ដែលគួរតែនៅបន្តជាប់ឃុំបណ្តោះអាសន្ន។ ការធ្វើដូច្នេះ គឺជាការមិនសមហេតុផលទាល់តែសោះ ដោយសារផ្ទុយនឹងកាតព្វកិច្ចច្បាស់លាស់របស់វិធានដែលគ្រប់គ្រងអង្គជំនុំជម្រះនេះ[20]។ ការចេញសេចក្តីសម្រេចបែបនេះ ក្នុងស្ថានភាពបែបនេះបង្កើតបានជាការរំលោភអំណាចដោយអង្គជំនុំជម្រះនេះ។

១៨. វិធីធ្វើឡើង អបជ ខកខានក្នុងការទទួលស្គាល់ថា ពេលវេលាកំណត់ដ៏រឹតត្បិតក្នុងវិធាន ៦៨ មានជាសំខាន់ (ដោយជំទាស់: សម្រាប់តែ) សម្រាប់ការការពារជនជាប់ចោទ[21] ដែលការកំណត់ពេលវេលាបែបនេះ បង្ហាញពីសិទ្ធិរបស់គាត់ក្នុងការទទួលបានការកាត់ក្តីដោយពេលវេលាសមស្រប ហើយសំខាន់ទៀតនោះ គឺគោរពតាមតាមគោលការណ៍ឃុំខ្លួនបណ្តោះអាសន្ន ដូចមានក្នុងដំណោះស្រាយខ្ពស់បំផុត (ulrimum remedium)។ ជនជាប់ចោទ មានសិទ្ធិទទួលបានសេចក្តីសម្រេច (មានសំអាងហេតុ) ដោយ អបជ លើបណ្តឹងឧទ្ធរណ៍របស់ខ្លួនក្នុងរយៈពេលបួនខែ ព្រោះតែការឃុំខ្លួនបណ្តោះអាសន្នគឺជាបន្ទុកដ៏ធ្ងន់លើបុគ្គលមួយ និងមិនត្រូវចាត់ទុកថា មិនមែនធម្មតាទេ ប៉ុន្តែខុសពីធម្មតា។

---

[20] ក្នុងករណី អបជ៖ វិធានផ្ទៃក្នុង និងលក្ខខណ្ឌរបស់វិធាននោះក្នុងការផ្តល់សេចក្តីសម្រេចដែលមានសំអាងហេតុ។

[21] ពិតណាស់ពេលវេលាកំណត់តឹងរឹង ក៏បានផ្តល់ប្រយោជន៍មួយ ចំនួនផងដែរ ដូចជាធ្វើឲ្យដំណើរការនីតិវិធី បញ្ចប់ក្នុងរយៈពេលមួយដែលសមស្រប, សូមមើលវិធាន ២១(៤)។ ប៉ុន្តែវាច្បាស់ ណាស់ថា ផលប្រយោជន៍របស់ជនជាប់ចោទ គឺជាក្តីបារម្ភជាចំបង ដូចមានចែងក្នុងវិធាន៦៨។ ក្តីបារម្ភនេះ កើតចេញពីការ សង្កេតដែលថាដីកាឃុំខ្លួនបណ្តោះអាសន្ន លែងមានអនុភាពទៀតហើយបន្ទាប់ពីរយៈពេល៤ខែបានកន្លងផុតទៅដោយគ្មានការអន្តរាគមន៍ផ្នែកតុលាការអ្វីទាល់តែសោះ។ ករណីនេះ ស្តែងឲ្យឃើញពីការលម្អៀងយ៉ាងខ្លាំងប្រឆាំងទៅនឹងផលប្រយោជន៍របស់ ជនជាប់ចោទ។ សេចក្តីសន្និដ្ឋាននេះ ត្រូវបានគាំទ្របន្ថែមទៀតដោយមាត្រា២៤៩ នៃCCP ដែលមិនគ្រាន់តែបានចែងពីការអស់ អនុភាពនៃការឃុំខ្លួនបណ្តោះអាសន្នប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានសង្កត់ធ្ងន់ថា បន្ទាប់ពីរយៈពេលបួនខែ ជនជាប់ចោទ "ត្រូវតែបានគេដោះលែងជាស្វ័យប្រវត្តិ"។ ដូច្នេះមាត្រា២៤៩នេះបានផ្តល់ការពន្យល់បន្ថែមទៀត (យ៉ាងច្រើនលើសលប់ដោយសមហេតុផល) ថា រយៈពេលកំណត់៤ខែ គឺដើម្បីការពារផលប្រយោជន៍របស់ជនជាប់ចោទ។ វិធាន៦៨ នៃវិធានផ្ទៃក្នុង គួរតែត្រូវបានគេបកស្រាយឲ្យបានត្រឹមត្រូវ និងស្របតាមស្ថានភាពជាក់ស្តែង។

១៩. វិធានដែលអនុវត្តដោយ អបជ នាំទៅរកលទ្ធផលផ្ទុយនឹងច្បាប់។ អបជ ចាំបាច់ត្រូវតែចេញសេចក្តីសម្រេចក្នុងរយៈពេលបួនខែ (ដោយមិនមានផលប្រយោជន៍សម្រាប់ជនជាប់ចោទដែលនឹងត្រូវទទួលបានប្រសើរជាងផលប្រយោជន៍ផ្សេងទៀត តាមនិយមន័យ) តាមរយៈច្បាប់ដែលមានគោលបំណង*ការពារ* ផលប្រយោជន៍ជនជាប់ចោទ។ ក្នុងការព្យាយាមដើម្បីគោរពពេលកំណត់នេះ ខ្លួន*បានធ្វើឲ្យប៉ះពាល់* ផលប្រយោជន៍ជនជាប់ចោទទៅវិញ តាមរយៈការចេញសេចក្តីសម្រេចដោយមិនមានសំអាងហេតុ ដោយមិនគោរពដល់បញ្ញត្តិ និងគោលគំនិតនៃវិធានផ្ទៃក្នុង នៅក្នុងការប៉ុនប៉ងដើម្បីធានាដល់ការពន្យារពេលឃុំខ្លួនបណ្តោះអាសន្ន ដែលគាត់នឹងត្រូវបានដោះលែងបើពុំមានសេចក្តីសម្រេចបែបនេះ។

២០. ការអនុវត្តរបស់ អបជ បង្ហាញពីការយល់មិនត្រឹមត្រូវលើគោលការណ៍ ដំណោះស្រាយខ្ពស់បំផុត (ulrimum remedium) ដូចបានបង្ហាញ (ផងដែរ) នៅមាត្រា៦៨។ ការឃុំខ្លួនបណ្តោះអាសន្នគឺមិនមែនដើម្បីតែឃុំខ្លួននោះទេ ប៉ុន្តែ អបជ ព្រមទាំង កសចស តែងតែធ្វើដូចនេះ។ សំខាន់ជាងនេះទៅទៀត នេះមិនមែនជាលើកទីមួយទេ ដែល អបជ បានបង្ហាញពីភាពលម្អៀងដែលមិនអាចការពារបាន ចំពោះការបន្តរក្សាឃុំខ្លួន **នួន ជា** គឺថា៖ ខ្លួនបានអនុវត្តក្នុងរបៀបស្រដៀងគ្នានេះនៅក្នុងអំឡុងពេលប៉ុន្មានខែរហូតដល់ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១០។ ក្នុងរយៈពេលនោះ ខ្លួនបានចាប់ផ្តើមទទួលយកអនុវត្តចេញសេចក្តីសម្រេច[22] ដោយមិនមានសំអាងហេតុ ដោយចេញសំអាងហេតុ

---

[22] ឯកសារ **D-140/9/4** PTC សេចក្តីម្រេចលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតបដិសេធសំណើរបស់គាត់ក្នុងការតែងតាំងអ្នកជំនាញផ្នែកប្រជាសាស្ត្របន្ថែមទៀតដើម្បីពិនិត្យឡើងវិញ នូវអង្គហេតុនៃរបាយការណ៍អ្នកជំនាញដែលដាក់ដោយអ្នកស្រី Ewa Tabeau និងលោក They Kheam, ឯកសារ **D-193/5/4** PTC, "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំឲ្យមាន កិច្ចស៊ើបសួរទាក់ទងទៅនឹងទ្រព្យសម្បត្តិរបស់ជនត្រូវចោទ " ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ ឯកសារ ERN 00528319-00528321 (សំអាងហេតុផ្តល់ឲ្យតាមក្រោយ នៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០១០ [៥៦ថ្ងៃ], ឯកសារ **D-310/1/2** PTC, "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាបដិសេធសំណើសុំស្តាប់ចម្លើយបុគ្គលដែលមានឈ្មោះ ក្នុងសំណើសុំបើកកិច្ចស៊ើបសួរទាក់ទងនឹងការរៀបការ និងការបាត់ខ្លួនដោយបង្ខំ " ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០, ឯកសារ ERN 00527487-00527489,(សំអាងហេតុផ្តល់ឲ្យតាមក្រោយ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ ២០១០ [៤២ថ្ងៃ], ឯកសារ **D-348/2/2** PTC,"សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាបដិសេធលើសំណើសុំបើកកិច្ចស៊ើបសួរទាក់ទងនឹងការរៀបការ និងការបាត់ខ្លួនដោយបង្ខំនៅស-២៤" ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០, ឯកសារ ERN 00527490-00527493 និង ឯកសារ **D-348/2/5** PTC, "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបើកកិច្ច ស៊ើបសួររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងសាក្សីដែលបានឃើញការរៀបការដោយបង្ខំនៅ ស-២៤" បន្ទាប់ ពីសារណាបន្ថែម,ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១០, ឯកសារ ERN 00548805-

00548808 (សំអាងហេតុផ្តល់ឲ្យតាមក្រោយ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១០[៥០ថ្ងៃ]), ឯកសារ**D-356/2/8** PTC, "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ កសចស បដិសេធសំណើសុំយោបល់អ្នកជំនាញទី២" ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០, ឯកសារERN 00527506-00527508 (សំអាងហេតុផ្តល់ឲ្យតាមក្រោយ ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១០ [២២ថ្ងៃ]), ឯកសារ **D-263/2/5** PTC, "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតច្រានចោលសំណើសុំឲ្យ អបជ ធ្វើមោឃៈភាពការស៊ើបសួរទាំងអស់, ឯកសារ (D263/1), ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០១០,ឯកសារ ERN 00529255-00529258 (សំអាងហេតុផ្តល់ឲ្យតាមក្រោយ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០ [១៥ថ្ងៃ]), ឯកសារ **D-264/2/5** PTC, "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងដីការបស់សហចៅក្រមស៊ើបអង្កេត បដិសេធចោលសំណើសុំផ្អាកនីតិវិធីដោយសារមូលហេតុរំលោភនីតិវិធី, ឯកសារ(D264/1), ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១០ ឯកសារ ERN 00529259-00529262 (សំអាងហេតុផ្តល់ឲ្យតាមក្រោយ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ [៦១ថ្ងៃ]) , ឯកសារ **D-370/2/10** PTC "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង 'ដីកាសម្រេចលើសំណើសុំដាក់ឯកសារសំណុំរឿងទាក់ទងនឹងសកម្មភាពពិតប្រាកដរបស់លោក ខៀវ សំផន" ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១១, ERN 00528315-00528 318 (សំអាងហេតុផ្តល់នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១០ (២៧ថ្ងៃក្រោយ) ។ ឯកសារ **D-361/2/3** អបជ "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹងដីកាសម្រេចរបស់ កសចស លើសំណើរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ សុំបំពេញកិច្ចស៊ើបអង្កេតទៅលើតួនាទីរបស់ លោក Ysa Osman នៅក្នុងការស៊ើបសួរ, ការច្រានចោលនូវកំណត់ហេតុនៃការស្តាប់ចម្លើយរបស់សាក្សីជាក់លាក់មួយចំនួន និងសំណើសុំពិនិត្យឡើងវិញនូវកំណត់ហេតុនៃការស្តាប់ចម្លើយរបស់សាក្សីជាក់លាក់មួយចំនួន" ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១០ ERN 00531063-00531066 (សំអាងហេតុផ្តល់នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១០ (៧៥ថ្ងៃក្រោយ) ។ ឯកសារ **D-300/1/6** អបជ "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ កសចស លើសេចក្តីណែនាំឲ្យពិចារណាឡើងវិញលើសំណើ D153, D172, D174, D178 និង D284" ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១០, ERN 00546144 (សំអាងហេតុផ្តល់នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១០ (១៥ថ្ងៃក្រោយ) ។ ឯកសារ **D-365/2/16** អបជ "សេចក្តីសម្រេចលើការពិចារណាឡើងវិញលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសំណើសុំដាក់ភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលអាចជួយដល់បង្ហាញពីយល់ដឹងរបស់ជនជាប់ចោទនៃឧក្រិដ្ឋកម្មនានា" ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១០, ERN 00549333-00549337 (សំអាងហេតុផ្តល់នៅក្រោយការចេញដីកាដំណោះស្រាយ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១០ (៧៦ថ្ងៃក្រោយ) ។ ឯកសារ **D-375/1/7** អបជ "សេចក្តីសម្រេចស្តីពីការដាក់សេចក្តីសន្និដ្ឋានបន្ថែមនៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើរបស់ នួន ជា សុំស្តាប់ចម្លើយសាក្សី" ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០១០ ERN 00554469-00554471 (សំអាងហេតុផ្តល់នៅក្រោយការចេញដីកាដំណោះស្រាយ គឺនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ (៦៩ថ្ងៃក្រោយ) ។ ឯកសារ **D-390/1/2/3** អបជ "សាលដីកាលើ បណ្តឹងឧទ្ធរណ៍ជាបន្ទាន់របស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់ កសចស ដោយបានបដិសេធមិនទទួលការដាក់ចម្លើយតបរបស់ អៀង សារី ទៅនឹងសេចក្តីសន្និដ្ឋានស្តាពរក្រោមវិធាន ៦៦ របស់សហ ព្រះរាជអាជ្ញា និង ការកត់សម្គាល់បន្ថែម និងសំណើសុំផ្អាកនីតិវិធី" ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០ ERN 00601742-00601742 (សំអាងហេតុផ្តល់នៅក្រោយការចេញដីកាដំណោះស្រាយ គឺនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ (១១ថ្ងៃក្រោយ) ។ អបជ "សេចក្តីសម្រេចលើសេចក្តីបន្ថែមចំពោះ សំណើរបស់ នួន ជា សុំប្តឹងជំទាស់ចៅក្រម យូ ប៊ុនឡេង" ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ២០១០ ERN 00577612-00577615 (សំអាងហេតុត្រូវបានផ្តល់នៅក្រោយថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១០ (៣៩ថ្ងៃក្រោ) ។

នៅពេលក្រោយ បើទោះជាគ្មានវិធានណាមួយអនុញ្ញាតលទ្ធភាពបែបនេះក៏ដោយ[23]។ បើទោះជាមិនត្រូវបានអះអាងជាក់ស្តែង ណាមួយក៏ដោយ ប៉ុន្តែវាជាការច្បាស់ណាស់សម្រាប់គ្រប់ភាគីទាំងអស់ថា ខ្លួនធ្វើបែបនេះក្នុងការប៉ុនប៉ងអនុញ្ញាតឱ្យ សចស ចេញដីកាដំណោះស្រាយនៅមុនថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១០ ជាថ្ងៃដែល **នួន ជា** នឹងត្រូវបានឃុំខ្លួនសម្រាប់រយៈពេលបីឆ្នាំ និងត្រូវបានដោះលែងបើពុំមានដីកាដំណោះស្រាយ។

២១. ភាពមមារញ៉ើកក្រៃលែងរបស់ កសចស ក្នុងការចេញដីកាដំណោះស្រាយក្នុងរយៈពេលបីឆ្នាំនេះ បង្ហាញការគោរពមិនត្រឹមត្រូវលើគោលការណ៍ ដំណោះស្រាយខ្ពស់បំផុត (ulrimum remedium)។ ការយកចិត្តទុកដាក់ជាចំបងរបស់ កសចស ក្នុងការអនុវត្តន៍ការស៊ើបអង្កេតរបស់ខ្លួន គួរតែត្រូវបានបញ្ចប់ការស៊ើបអង្កេតរបស់ខ្លួនតាមរបៀបអាចទទួលយកបាន ជាជាងការប្រឹងប្រែងឱ្យបានចប់ការស៊ើបអង្កេតក្នុងរយៈពេលបីឆ្នាំដែលបានដៅទុក ដើម្បីការពារមិនឱ្យមានការដោះលែង **នួន ជា**។ អបជ បន្ទាប់មកបន្តការគាំទ្រ កសចស ក្នុងការយល់មិនត្រឹមត្រូវនេះ ដោយចេញសេចក្តីសម្រេច មិនមានសំអាងហេតុ[24]។ ឬអាចនិយាយថា នេះមិនមែនជាលើកដំបូងទេដែល អបជ បានជ្រើសរើសការអនុវត្តការអានមិនសុក្រិតនូវវិធានដើម្បីសម្រួលដល់ការបន្តឃុំខ្លួន **នួន ជា**។

២២. ជាថ្មីម្តងទៀត ផ្ទុយទៅវិញមេធាវីការពារក្តីមិនបានអះអាងថាការពន្លឿនផ្នែកយុត្តិធម៌ មិនមែនជាអ្វីដែលត្រូវតែសោកស្តាយនោះទេ ។ តែការពន្លឿន ផ្នែកយុត្តិធម៌ ជាមួយនឹងគោលបំណងតែមួយ

---

[23] ពិតណាស់ វិធាន៧៧(១៤) ក៏មានចែងពីសេចក្តីសម្រេចបែបនេះផងដែរ ដូច្នេះ នៅពេលចេញសេចក្តីសម្រេចនេះ វាគួរតែមានសំអាងហេតុត្រឹមត្រូវ។

[24] ទង្វើរបស់ អបជ នៅពេលនេះ គឺមាន "គ្រោះថ្នាក់" តិចជាងសេចក្តីសម្រេចដែលគ្មានសំអាងហេតុកាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ព្រោះសេចក្តីសម្រេចទាំងនោះ មិនមានអនុភាពដោយផ្ទាល់ទៅលើការឃុំខ្លួនបណ្តោះអាសន្នប្រឆាំងលោក នួន ជា ឡើយ ហើយសំអាងហេតុភាគច្រើន ត្រូវបាបផ្តល់ឱ្យ *មុន* ការចេញដីកាដំណោះស្រាយ។ ប៉ុន្តែការផ្តល់សេចក្តីសម្រេចដែលគ្មានសំអាងហេតុនេះ បានបង្ហាញពីការមិនគោរពចំពោះ គោលការណ៍ដំណោះស្រាយខ្ពស់បំផុត។ ជាងនេះទៅទៀត ក្នុងដីកាពីឬបីទៀត(**D-365/2/16**, **D-375/1/7** និង **D-390/1/2/3**, សូមមើលលេខយោង២២ខាងលើ) សំអាងហេតុបន្ថែម ត្រូវបានផ្តល់ឱ្យតែ *ក្រោយ* ពីការចេញដីកាដំណោះស្រាយតែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត ប្រសិនបើ អបជ មិនបានចេញដីកា "ដែលគ្មានសំអាងហេតុ" ទេនោះ (មិនមែនជារឿងត្រឹមត្រូវដែលត្រូវធ្វើ បើពិចារណាដល់វិធានផ្ទៃក្នុង) ម្ល៉េះសមលោក នួន ជា ត្រូវបានគេដោះលែងឱ្យនៅក្រៅឃុំកាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១០ បាត់ទៅហើយ (ជារឿងត្រឹមត្រូវដែលត្រូវធ្វើ បើពិចារណាដល់វិធានផ្ទៃក្នុង) ព្រោះការចេញដីកាដំណោះស្រាយ នឹងមិនអាចទៅរួចទេ ប្រសិនបើគ្មានសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ទាំងអស់។ ដូច្នេះ សកម្មភាពនេះ ពិតជាបានប៉ះពាល់ដល់ផលប្រយោជន៍របស់លោក នួន ជា។

គត់ ក្នុងការរក្សាជនជាប់ចោទនៅក្នុងមន្ទីរឃុំឃាំង និងមិនអើពើទាល់តែសោះចំពោះបទប្បញ្ញត្តិនៃវិធានផ្ទៃក្នុង ផលប្រយោជន៍របស់ជនជាប់ចោទ គោលការណ៍ ដំណោះស្រាយខ្ពស់បំផុត (ulrimum remedium) ត្រូវបានគោរពយ៉ាងត្រឹមត្រូវតាមច្បាប់។ ប្រសិនបើគោលបំណងមួយរបស់តុលាការនេះ គឺស្តារឡើងវិញនូវទំនុកចិត្តចំពោះនីតិរដ្ឋ តុលាការនេះត្រូវគោរពវិធានរបស់ខ្លួន និងមិនត្រូវពាក់ព័ន្ធជាមួយការអនុវត្តវិធានដែលមានលក្ខណៈ ប្រឌិត និង ខូចប្រយោជន៍ដល់ជនជាប់ចោទឡើយ ។

## ឃ. សេចក្តីសម្រេចឃុំខ្លួនមិនមានសំអាងហេតុ

២៣. មូលដ្ឋានដាច់ដោយឡែកសម្រាប់សំណើសុំដោះលែងជាបន្ទាន់ ដោយសារតែសេចក្តីសម្រេចមិនមានសំអាងហេតុជាក់លាក់ទៅនឹងមូលដ្ឋាន និងមូលហេតុសម្រាប់ការបន្តឃុំខ្លួន[25]។ បើទោះជាវិធានមិនចែងច្បាស់ឱ្យ អបជ ផ្តល់សំអាងហេតុសម្រាប់ការឃុំខ្លួនបន្តក៏ដោយ ក៏កាតព្វកិច្ចបែបនេះមានក្នុងប្រព័ន្ធវិធានផ្ទៃក្នុង ដែលត្រូវចាត់ទុកថាសម្រាប់អនុវត្តគ្រប់វិធានទាំងអស់។ អនុលោមតាមវិធាន *រាល់*សេចក្តីសម្រេចផ្សេងទៀតលើការឃុំខ្លួនបណ្តោះអាសន្នត្រូវតែមានសំអាងហេតុ[26]។ អនុលោមតាមគោលការណ៍នីត្យានុកូលភាព គ្មានហេតុផលជាគោលការណ៍អនុញ្ញាត អបជ មិនគោរពតាមតម្រូវការដូចគ្នានូវគោលការណ៍ដំណោះស្រាយខ្ពស់បំផុត (ulrimum remedium) នេះទេ និងតម្រូវការដើម្បីចេញសេចក្តីសម្រេចមានសំអាងហេតុក្នុងលក្ខខណ្ឌទូទៅ។ អាស្រ័យហេតុនេះ ការពិតដែលថា អបជ មិនគ្រាន់តែខកខាន មិនបានផ្តល់សំអាងហេតុលើសេចក្តីសម្រេចប៉ុណ្ណោះទេ តែថែមទាំងខកខានមិនបានផ្តល់ហេតុផលណាមួយសម្រាប់សមាសភាពការឃុំខ្លួនបណ្តោះអាសន្ន និងថែមទាំងគាំទ្រការសេចក្តីសន្និដ្ឋានបន្តឃុំខ្លួន **នួន ជា** ដែលខ្វះមូលដ្ឋានច្បាប់គ្រប់គ្រាន់។

## ង. ការពន្យារពេលឃុំខ្លួនបណ្តោះអាសន្ន នួន ជា បន្តទៅទៀត គឺខុសច្បាប់

២៤. ការបន្តឃុំខ្លួន **នួន ជា** បន្ថែមទៀត នឹងខុសច្បាប់ ដោយសារតែគ្មានមូលដ្ឋានច្បាប់ជាធរមាន

---

[25] ខណៈពេលដែលផ្នែកនេះ មានមូលហេតុដាច់ដោយឡែកទាក់ទងនឹងសំណើសុំនៅក្រៅឃុំ គេចាំបាច់ត្រូវតែយល់វាផងដែរដើម្បីគាំទ្រផ្នែកដែលសំខាន់ជាងនេះទៀត ដូចជាការអះអាងពីការខ្វះសំអាងហេតុតាមផ្លូវតុលាការយ៉ាងធ្ងន់ធ្ងរបំផុតចំពោះសេចក្តីសម្រេចទាំងមូល។

[26] វិធាន ៤៤(២), ៥១(១) និង (៣), ៦៣(១)(ខ), ៦៣(៧), ៦៤(២) និងជាពិសេស ៦៨(១)។

សម្រាប់ការឃុំខ្លួនបន្ត។ ដូចនេះការដោះលែង **នួន ជា** ជាបន្ទាន់ គឺជាជម្រើសផ្លូវច្បាប់តែមួយគត់។

### ច. សំណើសុំឱ្យមានសវនាការជាបន្ទាន់

២៥. ពិតណាស់សំអាងហេតុរបស់ អបជ នឹងចេញក្នុងពេលឆាប់ៗនេះ។ វាជាការប្រសើរដើម្បីពន្យារពេលសវនាការ និងសេចក្តីសម្រេចលើសំណើនេះរហូតដល់ពេលដែល អបជ ចេញសំអាងហេតុ និងបន្ទាប់មកប្រកាសមិនទទួលយកសំណើនេះ។ វិធានបែបនេះនឹងមិនអាចទទួលយកបានទេ។ មូលហេតុសម្រាប់អង្គជំនុំជម្រះនេះ គឺច្បាស់ និងជាក់ស្តែង៖ គឺពុំមានសេចក្តីសម្រេចមានសំអាងហេតុ ដូចដែលតម្រូវដោយវិធាន៦៨ ក្នុងរយៈពេលបួនខែ ដូចនេះហើយ **នួន ជា** ត្រូវតែបានដោះលែង។ ពុំមានហេតុផលពន្យារដល់ការពិចារណាលើបញ្ហានេះទេ។ មេធាវីការពារក្តីស្នើសុំឱ្យមានសវនាការជាបន្ទាន់មួយ។ សហមេធាវីអន្តរជាតិ លោក Michiel Pestman នឹងស្នាក់នៅប្រទេសកម្ពុជារហូតដល់ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១១ នេះ។ អាស្រ័យហេតុនេះសវនាការមួយនៅពេលឬមុនកាលបរិច្ឆេទនេះ គឺជាពេលវេលាសមស្របបំផុត។

២៦. ក្នុងករណីដែល កសព និង អង្គជំនុំជម្រះសាលាដំបូងគិតថា សំណើនេះត្រូវតែទទួលយក និង **នួន ជា** ត្រូវតែបានដោះលែងភ្លាម នោះមេធាវីការពារក្តីសូមបោះបង់ចោលសំណើសុំសវនាការនេះ។

### V. សេចក្តីសន្និដ្ឋាន

២៧. អាស្រ័យដោយហេតុផលដែលបានលើកឡើងនៅក្នុងសំណើនេះ មេធាវីការពារក្តីស្នើសុំ អជសដ ឱ្យចេញដីកាដោះលែងលោក **នួន ជា** ជាបន្ទាន់។

សហមេធាវីរបស់លោក **នួន ជា**

**សុន អរុណ** | **Michiel PESTMAN & Victor KOPPE**